**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៤២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# មូលនិធិគន្ធបុប្ផាកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- យោងតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃ “**មូលនិធិគន្ធបុប្ផាកម្ពុជា**” សរសេរកាត់ថា “**ម.គ.ក.**” និង មានឈ្មោះជាអក្សរឡាតាំង “CAMBODIA KANTHA BOPHA

FOUNDATION" សរសេរកាត់ថា "**CKF**" ជាបរធនបាលកិច្ច ដើម្បីកៀរគរអំណោយ ឧបត្ថម្ភធន និងវិភាគទានពីគ្រប់ប្រភពស្របច្បាប់នានា ធានាចីរភាពនៃប្រភពចំណូលសម្រាប់ទ្រទ្រង់ផ្នែកហិរញ្ញវត្ថុចំពោះមន្ទីរពេទ្យគន្ធបុប្ផា ឱ្យអាចដំណើរការជាប្រក្រតី ប្រកបដោយនិរន្តរភាព បម្រើដល់គោលនយោបាយលើកកម្ពស់សុខុមាលភាពសង្គម របស់រាជរដ្ឋាភិបាលកម្ពុជា និងធានាឱ្យមន្ទីរពេទ្យគន្ធបុប្ផាគោរពបាននូវគោលការណ៍ទាំង ៤គឺ៖

- រក្សាកម្រិតបៀវត្សរ៍សមរម្យសម្រាប់បុគ្គលិក ដើម្បីធានាបានវិន័យ និងការយកចិត្តទុកដាក់ខ្ពស់របស់បុគ្គលិក
- រក្សាប្រព័ន្ធប្រតិបត្តិការ និងការគ្រប់គ្រងពិសេសសម្រាប់មន្ទីរពេទ្យនេះ
- បន្តអនុវត្តគោលការណ៍មិនយកកម្រៃសេវាសម្រាប់ការផ្តល់សេវាពិនិត្យ និងព្យាបាលទារកនិងកុមារ និង
- បន្តរក្សា និងពង្រឹងគុណភាពដែលមានស្រាប់។

**មាត្រា ២** .-

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធី ក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅនៃ ម.គ.ក.។

**មាត្រា ៣** .-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមូលនិធិគន្ធបុប្ផាកម្ពុជា។

**មាត្រា ៤** .-

បច្ចេកសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យ ដូចខាងក្រោម៖

- **បរធន** សំដៅដល់ទ្រព្យសម្បត្តិ ឬមូលនិធិ ដែលបានផ្ទេរឱ្យបរធនបាលគ្រប់គ្រង និងចាត់ចែង សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។
- **បរធនបាល** សំដៅដល់បុគ្គល ដែលទទួលសិទ្ធិគ្រប់គ្រង និងចាត់ចែងបរធន ពីបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។
- **បរធនបាលទាយក** សំដៅដល់បុគ្គលដែលបង្កើត និងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្តល់ទ្រព្យសម្បត្តិ ឬមូលនិធិដំបូងនៅក្នុងបរធនបាលកិច្ច។
- **បរធនបាលកិច្ច** សំដៅដល់កិច្ចការគ្រប់គ្រង និងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ២
## អត្តសញ្ញាណ ប្រភពធនធាន និងបរធនបាលកិច្ច នៃ ម.គ.ក.

**មាត្រា ៥** .-

ម.គ.ក. ជាបរធនបាលកិច្ច ដែលបង្កើតឡើង ដើម្បីស្វែងរកជំនួយមនុស្សធម៌ មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ សាសនា និន្នាការនយោបាយ និងបម្រើឱ្យផលប្រយោជន៍សាធារណៈ។

ម.គ.ក. អាចមានធនធានពីប្រភព ដូចតទៅ ៖

- វិភាគទានដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជា
- វិភាគទានប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ដែលបានគ្រោងក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល
- កម្រៃពីថ្លៃសំបុត្រចូលទស្សនាតំបន់រមណីយដ្ឋានអង្គរ និង
- អំណោយ និងវិភាគទានសប្បុរសធម៌ ពីគ្រប់ប្រភពស្របច្បាប់ផ្សេងៗទៀត។

**មាត្រា ៦** .-

បរធនបាលទាយករបស់មូលនិធិគន្ធបុប្ផាកម្ពុជា គឺរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

មូលនិធិគន្ធបុប្ផាកម្ពុជា មាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចកិត្តិព្រឹទ្ធ-បណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ជាស្ថាបនិក និងមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **លោកជំទាវបណ្ឌិត ពេជ ច័ន្ទមុន្នី ហ៊ុនម៉ាណែត** ជាប្រធានកិត្តិយស។

បរធនបាលកិច្ចត្រូវស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់ក្រុមប្រឹក្សាបរធនបាលនៃ ម.គ.ក.។

**មាត្រា ៧** .-

ម.គ.ក. មានរូបសញ្ញា និងត្រាដោយឡែក ក្នុងការបំពេញភារកិច្ចរបស់ខ្លួន តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាលនៃ ម.គ.ក.។

ម.គ.ក. មានទីស្នាក់ការកណ្តាលនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថិតនៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ករណីមានការផ្លាស់ប្តូរអាសយដ្ឋានអនាគត ជាកម្មវត្ថុនៃការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាលនៃ ម.គ.ក.។

## ជំពូកទី៣
## សមាជិកភាព នៃ ម.គ.ក.

**មាត្រា ៨** .-

ម.គ.ក. អាចមានសមាជិកតាមការចាំបាច់។ ការសម្រេចបញ្ចូលសមាជិកភាព ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល ផ្អែកតាមលក្ខណៈសម្បត្តិនៃបុគ្គលនីមួយៗ។

**មាត្រា ៩** .-

សមាជិក ម.គ.ក. មានបីប្រភេទគឺៈ

១. សមាជិកស្ថាបនិក

២. សមាជិកកិត្តិយស និង

៣. សមាជិកគាំទ្រ ។

ផ្អែកតាមការស្នើសុំរបស់សាមីជន សមាជិកកិត្តិយស និងសមាជិកគាំទ្រ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ អាចក្លាយជាសមាជិកក្រុមប្រឹក្សាបរធនបាល តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាលនៃ ម.ក.ក.។

លក្ខខណ្ឌនៃការទទួលបាន និងការបញ្ចប់នូវសមាជិកភាព ព្រមទាំងគុណវុឌ្ឍិសម្រាប់ក្លាយជាសមាជិកក្រុមប្រឹក្សាបរធនបាល នឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបរធនបាលនៃ ម.គ.ក.។

## ជំពូកទី ៤
## សមាសភាព រចនាសម្ព័ន្ធ តួនាទី និងសិទ្ធិអំណាច

**មាត្រា ១០ .-**

ក្រុមប្រឹក្សាបរធនបាលមានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រតិបត្តិ |
| ៤. រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៥. អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. ប្រធានមន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ | សមាជិក |
| ៧. ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ | សមាជិក |

សមាសភាពជាក់ស្តែងរបស់ក្រុមប្រឹក្សាបរធនបាល ត្រូវតែងតាំង និងផ្លាស់ប្តូរដោយអនុក្រឹត្យ សម្រាប់អាណត្តិ ៣ឆ្នាំ និងអាចបន្តទៀតបានតាមការស្នើសុំរបស់ក្រសួង-ស្ថាប័ន ដែលសមាជិកនោះជាតំណាង។

**មាត្រា ១១ .-**

ក្រុមប្រឹក្សាបរធនបាលមានតួនាទី សិទ្ធិ និងអំណាច ដូចខាងក្រោម៖

- ពិនិត្យ និងអនុម័តថវិកាប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុ របស់ ម.គ.ក.
- តាមដាន ត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃវឌ្ឍនភាពនៃកិច្ចដំណើរការរបស់ ម.គ.ក.
- អំពាវនាវ កៀរគរធនធានហិរញ្ញវត្ថុ និងសម្ភារៈនានា ជាសាធារណៈ ពីប្រភពនានាទាំងក្នុង និងក្រៅប្រទេស ដើម្បីបម្រើដល់គោលបំណង និងគោលដៅដូចមានចែងក្នុងមាត្រាខាងលើ
- រៀបចំគោលនយោបាយ និងនីតិវិធីផ្តល់ការឧបត្ថម្ភដើម្បីទ្រទ្រង់មន្ទីរពេទ្យគន្ធបុប្ផា
- គ្រប់គ្រង និងប្រើប្រាស់ថវិកាដែលទទួលបានពីការឧបត្ថម្ភ ឬការបរិច្ចាគ ឱ្យមានតម្លាភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីទទួលបាននូវជំនឿទុកចិត្តពីសាធារណជន
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគរបស់ ម.គ.ក. តាមច្បាប់ជាធរមាន
- សហការជាមួយស្ថាប័ន ឬមូលនិធិនានា រួមទាំងមូលនិធិគន្ធបុប្ផាស្វីស ដើម្បីការរីកចម្រើន និងចីរភាពនៃ ម.គ.ក.
- ដាក់ចេញនូវបែបបទ និងនីតិវិធីចាំបាច់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងកិច្ចដំណើរការនៃ ម.គ.ក.
- បង្កើតគណៈកម្មការ ឬក្រុមការងារ តាមការចាំបាច់ ដើម្បីបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**មាត្រា ១២ .-**

ដំណើរការការងាររបស់ក្រុមប្រឹក្សាបរធនបាល ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ ម.គ.ក.។

**មាត្រា ១៣ .-**

ក្រុមប្រឹក្សាភិបាល នៃ ម.គ.ក. ត្រូវប្រជុំការងារយ៉ាងតិច **២ដង** ក្នុងមួយឆ្នាំ ឬអាចប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល។ ករណីចាំបាច់ ប្រធានក្រុមប្រឹក្សាភិបាល អាចប្រគល់សិទ្ធិឱ្យអនុប្រធានណាម្នាក់ដឹកនាំកិច្ចប្រជុំជំនួស។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាចដំណើរការបាន លុះត្រាតែមានវត្តមានសមាជិកយ៉ាងតិចពីរភាគបី។

ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញតំណាងក្រសួង-ស្ថាប័ននានា ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល និងឥស្សរជននានា ដែលមានបទពិសោធន៍លើវិស័យវិទ្យាសាស្ត្រ សេដ្ឋកិច្ច ហិរញ្ញវត្ថុ សុខាភិបាល និងសង្គមកិច្ច ឱ្យចូលរួមប្រជុំបាន តែតំណាងទាំងនោះពុំមានសិទ្ធិបោះឆ្នោតឡើយ។

**មាត្រា ១៤ .-**

ការសម្រេចនានារបស់ក្រុមប្រឹក្សាភិបាល អាចទុកជាបានការ លុះត្រាតែមានសំឡេងគាំទ្រភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការរបស់ ម.គ.ក. និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលមានវត្តមាន។

## ជំពូកទី ៥
## អង្គភាពប្រតិបត្តិ នៃ ម.គ.ក

**មាត្រា ១៥ .-**

ម.គ.ក. មានអង្គភាពប្រតិបត្តិមួយ សម្រាប់អនុវត្តកិច្ចប្រតិបត្តិការប្រចាំថ្ងៃ របស់ ម.គ.ក.។

អង្គភាពប្រតិបត្តិ នៃ ម.គ.ក. មានតួនាទីដឹកនាំ និងគ្រប់គ្រងការអនុវត្តផែនការសកម្មភាព ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល នៃ ម.គ.ក. ដើម្បីសម្រេចគោលបំណងរបស់ ម.គ.ក.។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រតិបត្តិ នៃ ម.គ.ក. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា។

**មាត្រា ១៦ .-**

អង្គភាពប្រតិបត្តិ នៃ ម.គ.ក. ត្រូវគ្រប់គ្រងដោយនាយកប្រតិបត្តិ ១រូប ដែលជាថ្នាក់ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមាននាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

នាយកប្រតិបត្តិត្រូវតែងតាំង និងបញ្ចប់តំណែងដោយអនុក្រឹត្យ។ នាយករងត្រូវតែងតាំង និងបញ្ចប់តំណែងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា។

អង្គភាពប្រតិបត្តិ នៃ ម.គ.ក. អាចជ្រើសរើសមន្ត្រី ឬបុគ្គលិកកិច្ចសន្យាដែលមានគុណវុឌ្ឍិ ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់ ដើម្បីធានាបាននូវប្រសិទ្ធភាពការងាររបស់ខ្លួន។

**មាត្រា ១៧ .-**

អង្គភាពប្រតិបត្តិ នៃ ម.គ.ក. មានភារកិច្ចសម្របសម្រួល និងអនុវត្តការងារ ដូចតទៅ៖

- ត្រួតពិនិត្យលើការរក្សាកំណត់ត្រាហិរញ្ញវត្ថុ ការរៀបចំលិខិតបញ្ជាក់ការទទួលមូលនិធិ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេប សម្រាប់ក្រុមប្រឹក្សាបរធនបាល នៃ ម.គ.ក.
- សម្របសម្រួលជាមួយក្រសួងសុខាភិបាល និងមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីផ្សព្វផ្សាយអំពីមូលនិធិគន្ធបុប្ផាកម្ពុជា និងការផ្សព្វផ្សាយពាក់ព័ន្ធនានា
- រៀបចំកម្មវិធីផ្សេងៗ តាមការចាំបាច់ សំដៅកៀរគរវិភាគទានពីសប្បុរសជន និង
- អនុវត្តភារកិច្ចដទៃទៀតតាមការណែនាំរបស់ក្រុមប្រឹក្សាបរធនបាល ម.គ.ក.។

## ជំពូកទី ៦
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ម.គ.ក.

**មាត្រា ១៨ .-**

ធនធានហិរញ្ញវត្ថុនៃ ម.គ.ក. ត្រូវរក្សាទុកនៅក្នុងគណនីរបស់ធនាគារណាមួយ តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាល នៅក្រោមឈ្មោះផ្ទាល់របស់គណនី ម.គ.ក. និងក្រោមរូបភាពផ្សេងជាការវិនិយោគដែលអនុម័តដោយក្រុមប្រឹក្សាបរធនបាល។

**មាត្រា ១៩ .-**

ចំណាយសម្រាប់ការប្រព្រឹត្តទៅ និងការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាបរធនបាល នៃ ម.គ.ក. និងអង្គភាពប្រតិបត្តិ អាចគ្រោងក្នុងគម្រោងថវិកាប្រចាំឆ្នាំ ដែលមានប្រភពពីថវិកាឧបត្ថម្ភរបស់រដ្ឋ ក្នុងកញ្ចប់ថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រភពស្របច្បាប់ផ្សេងៗទៀត។

**មាត្រា ២០ .-**

ការប្រើប្រាស់ ការទូទាត់ និងបើកប្រាក់ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាល នៃ ម.គ.ក.។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាល នៃ ម.គ.ក. អាចផ្តល់សិទ្ធិជូនអនុប្រធានប្រតិបត្តិ ឬនាយកប្រតិបត្តិ នៃ ម.គ.ក. ដើម្បីអនុវត្តការងារទូទាត់ និងបើកប្រាក់។

## ជំពូកទី ៧
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ២១ .-**

ការគ្រប់គ្រង និងប្រើប្រាស់ថវិការបស់ ម.គ.ក. ជាកម្មវត្ថុនៃការធ្វើសវនកម្ម ដោយសវនករឯករាជ្យ។

**មាត្រា ២២ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាលអាចចេញសេចក្តីសម្រេចស្តីពីនីតិវិធីអនុវត្តថវិកាលម្អិតបន្ថែម តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ ម.គ.ក.។

# ជំពូកទី ៨
# អវសានប្បញ្ញត្តិ

**មាត្រា ២៣ .-**

អនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៨ ស្ដីពីការបង្កើតមូលនិធិគន្ធបុប្ផាកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ